01106916

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 06 / 2015
ម៉ោង (Time/Heure): 14:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E335/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥

**ផ្ញើជូន៖** ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

**មកពី៖** លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) សុំឲ្យទទួលយកឯកសារនានាដែលទាក់ទិននឹងសាក្សី ថេត សម្បត្តិ

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយពីមេធាវីការពារក្តី ខៀវ សំផន ("សំណើ") សុំដាក់ឯកសារចំនួនបីទៅក្នុងសំណុំរឿង និង ទទួលយកឯកសារទាំងនោះជាភស្តុតាងអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E335/4 កថាខណ្ឌ ៥)។ ឯកសារទាំងនោះរួមមាន (១) អត្ថបទរបស់សារព័ត៌មាន Cambodia Daily សរសេរដោយលោក George Wright មានចំណងជើងថា "អ្នកសារព័ត៌មានត្រូវបានស្នើជាថ្មីម្តងទៀតឱ្យផ្តល់សក្ខីកម្មនៅសាលាក្តីខ្មែរក្រហម" ចុះផ្សាយថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៥ (ឯកសារ E335/4.1) (២) អត្ថបទរបស់សារព័ត៌មាន Cambodia Daily សរសេរដោយលោក George Wright មានចំណងជើងថា "អ្នកសារព័ត៌មាននឹងឡើងផ្តល់សក្ខីកម្មនៅ អ.វ.ត.ក ប្រសិនបើមេដឹកនាំបរទេសមកផ្តល់សក្ខីកម្មដែរ" ចុះផ្សាយថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ (ឯកសារ

E335/4.2) និង (៣) កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី Robert T. F. Lemkin នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ (ឯកសារ F2/4/3/1)។ មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា ឯកសារទាំងនោះ មិនអាចរកបាននៅមុនពេលបើកសវនាការទេ ហើយថា ឯកសារទាំងនោះមានប្រយោជន៍ សម្រាប់នាំមកនូវការស្វែងរកការពិត (ឯកសារ E335/4 កថាខណ្ឌ ៤)។ លើសពីនេះទៀត មេធាវីការពារក្តីរបស់ ខៀវ សំផន បានអះអាងថា ឯកសារទាំងនោះជាប់ពាក់ព័ន្ធនឹងសក្ខីកម្ម របស់ ថេត សម្បត្តិ នាពេលខាងមុខ (ឯកសារ E335/4 កថាខណ្ឌ ៥)។ ក្នុងករណីនេះ អត្ថបទសារព័ត៌មានទាំងពីរខាងលើពាក់ព័ន្ធនឹងព័ត៌មានដែល ថេត សម្បត្តិ បានយកជា មូលដ្ឋានដើម្បីផលិតភាពយន្តឯកសាររបស់គាត់ដែលមានចំណងជើងថា "នៅពីក្រោយវាល ពិឃាត" (ឯកសារ E3/4202) "សត្រូវរបស់ប្រជាជន" (ឯកសារ E3/4001R) និង "Suspicious Minds" (ឯកសារ E335/4 កថាខណ្ឌ ៦)។ កំណត់ហេតុជាលាយលក្ខណ៍ អក្សរនៃការស្តាប់ចម្លើយរបស់លោក Lemkin ត្រង់ចំណុចដែលពាក់ព័ន្ធនឹងការសហការ របស់គាត់ជាមួយ ថេត សម្បត្តិ រួមទាំងការរៀបចំភាពយន្តឯកសារនានាដែលបានលើកឡើង ខាងលើ ក៏ជាឯកសារដែលអាចយកមកធ្វើការដេញដោលដែរ (ឯកសារ E335/4 កថាខណ្ឌ ៧)។ ភាគីផ្សេងទៀតមិនបានដាក់ចម្លើយតបទេ។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយក ភស្តុតាងថ្មីដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ អង្គជំនុំជម្រះនឹងធ្វើ សេចក្តីសម្រេចចំពោះសំណើសុំបញ្ចូលភស្តុងតាងថ្មីនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅ ក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ បន្ថែមពីលើនេះ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ចែងថា គ្រប់ភាគីដែលបានស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រូវតែបញ្ជាក់ពីមូលហេតុនៃការស្នើសុំនោះ ឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំ ត្រូវធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថាភស្តុតាងថ្មីដែលបាន ស្នើនោះមិនអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះ ឬ មិនអាចរកបានទោះបីជាបានខិតខំ ស្វែងរកដោយសមស្របហើយក៏ដោយ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងអាច ទទួលយកភស្តុតាងនៅចំពោះមុខខ្លួនបាន ទោះបីជាភស្តុតាងទាំងនេះពុំបានបំពេញលក្ខខណ្ឌ តម្រូវ នៅពេលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ (ឯកសារ E289/2 កថាខណ្ឌ ៣ និង ឯកសារ E172/24/5/1 កថាខណ្ឌ ៣)។ ករណីទាំងនេះ រួមមានករណីដែលភស្តុតាងមាន ទំនាក់ទំនងជិតស្និទ្ធទៅនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ (ឯកសារ

E289/2 កថាខណ្ឌ ៣ និង ឯកសារ E172/24/5/1 កថាខណ្ឌ ៣)។

៣. តាំងពីដំបូងមក អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី Robert T.F. Lemkin ត្រូវបានដាក់ក្នុងសំណុំរឿង ០០២ រួចហើយ (ឯកសារ F2/4/3/1)។ ឯកសារពីរផ្សេងទៀតដែលត្រូវសម្រេចដោះស្រាយ ចុះថ្ងៃទី ១៦ និងទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ មិនអាចរកបាននៅមុនពេលបើកសវនាការនោះទេ។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ឯកសារទាំងនេះមានព័ត៌មានអំពីតួនាទីរបស់ជនជាប់ចោទនៅពេលវេលាពាក់ព័ន្ធ រួមទាំងការដឹងរបស់ពួកគេអំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហម។ លើសពីនេះទៀត ព័ត៌មាននេះបន្ថែមទៅលើចំណុចផ្សេងៗទៀតនៃភស្តុតាងដែលបានមកពី ថេត សម្បត្តិ ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ នៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះ (សូមមើល ឯកសារ E3/4202 និង ឯកសារ E3/4001R)។ ទាក់ទិននឹងចំណុចខាងលើ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការដាក់ឯកសារទាំងបីនៅចំពោះមុខខ្លួន នឹងមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។

៤. លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណអត្ថបទសារព័ត៌មានចំនួនបួនបន្ថែមទៀត ដែលបានចុះផ្សាយនៅចន្លោះពីថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៤ ដល់ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៥ ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ អង្គជំនុំជម្រះសូមយោងទៅឯកសារទាំងនេះ (១) អត្ថបទមួយនៅក្នុងទិន្នានុប្បវត្តិ Harvard ដែលមានចំណងជើងថា "Deep into bloody history" ចុះផ្សាយថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៤ (២) អត្ថបទរបស់វិទ្យុវីអូអេជាភាសាខ្មែរដោយ សុខ ខេមរា ដែលមានចំណងជើងថា "Nuon Chea's Defense Finds Grounds To Appeal at Least One crime Accusation" ចុះផ្សាយនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ (៣) អត្ថបទរបស់សារព័ត៌មាន Cambodia Daily ដែលសរសេរដោយលោក Julia Wallace ដែលមានចំណងជើងថា "Nuon Chea Seeks Testimony of Filmmakers" ចុះផ្សាយនៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៤ និង (៤) អត្ថបទរបស់វិទ្យុវីអូអេជាភាសាខ្មែរដោយ សុខ ខេមរា ដែលមានចំណងជើងថា "Journalist Wants To testify at Tribunal" ចុះផ្សាយនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៥។

៥. អង្គជំនុំជម្រះយល់ឃើញថា ការដាក់ឯកសារទាំងនេះទៅក្នុងសំណុំរឿង រួមជាមួយឯកសារ

នានាដែលត្រូវបានស្នើសុំដោយមេធាវីការពារក្ដី ខៀវ សំផន ជាការចាំបាច់ក្នុងការផ្ដល់នូវរូបភាពកាន់តែពេញលេញអំពីបញ្ហានានាដែលពាក់ព័ន្ធ ដែលមាននៅក្នុងឯកសារទាំងនោះ។ ហេតុដូច្នេះ តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន អង្គជំនុំជម្រះយល់ថា ជាការសមស្របដែលត្រូវដាក់អត្ថបទសារព័ត៌មានទាំងបួនខាងលើនៅចំពោះមុខខ្លួន រួមជាមួយនឹងសម្ភារៈឯកសារនានានៅក្នុងសំណើ។

៦. អនុស្សរណៈនេះជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E335/4។